ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី២ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០

រៀបចំដោយៈ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយៈ ថវិកាជាតិ

## ១. សេចក្ដីផ្ដើម៖

នៅព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី២ សម្រាប់ឆ្នាំ២០២០ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមជាគណៈអធិបតី **ឯកឧត្តម ធា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និង ជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ណែនាំដល់សមាជិកក្រុមប្រឹក្សាបច្ចេកទេសស្ដីពីការរៀបចំសកម្មភាព និងផែនការថវិកាសម្រាប់ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២១ តាមក្រសួង ស្ថាប័ន។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

**ឯកឧត្តម ធា ផលា** បានណែនាំថា ការរៀបចំផែនការនេះត្រូវស្របតាមសេចក្ដីជូនដំណឹងលេខ២១៣ ផែនការយុទ្ធសាស្ត្រជាតិ និងមានលក្ខណៈពហុវិស័យ ប៉ុន្តែផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលក៏មានលក្ខណៈពហុវិស័យ និងផែនការយុទ្ធសាស្ត្រមិនមែនវិស័យសុខាភិបាលក៏មានលក្ខណៈពហុវិស័យ។

ឯកឧត្តម បានបញ្ជាក់ទៀតថា យើងកំពុងស្ថិតក្នុងអន្តរកាលឆ្ពោះទៅចីរភាព មានន័យថា ចេញពីការប្រើប្រាស់មូលនិធិជំនួយច្រើន មកប្រើប្រាស់មូលនិធិរាជរដ្ឋាភិបាលច្រើនជាងមុន គឺប្រើប្រាស់ថវិកាដែលមានស្រាប់ហើយឱ្យត្រូវច្បាប់។

ជាកិច្ចចាប់ផ្ដើម **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក-សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក និងតាមពេលវេលាកំណត់។

ឯកឧត្តម បានផ្ដល់ជាទស្សនទាន ពាក់ព័ន្ធជាមួយការរៀបចំផែនការសកម្មភាពឆ្លើយតបមេរោគអេដស៍ដើម្បីបញ្ជ្រាបក្នុងផែនការសកម្មភាពរបស់ក្រសួងនីមួយៗ ត្រូវស្របតាមនីតិវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដូចជា ត្រូវមានគោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធី ហើយសកម្មភាពឆ្លើយតបមេរោគអេដស៍ អាចស្ថិតនៅក្នុងអនុកម្មវិធីណាមួយដើម្បីសម្រេចកម្មវិធី និងរួមចំណែកសម្រេចគោលបំណងនៃគោលនយោបាយណាមួយរបស់សាមីក្រសួង ដែលជាសមាជិកក្រុមប្រឹក្សាបច្ចេកទេស ជាពិសេសការរៀបចំផែនការសកម្មភាពត្រូវស្របតាមវដ្តនៃការរៀបចំថវិកា។

ការប៉ាន់ប្រមាណការចំណាយត្រូវបញ្ចប់ត្រឹមខែមីនា ផែនការយុទ្ធសាស្ត្រថវិកាចាប់ផ្តើមពីខែមេសា និងបញ្ចប់នៅខែកក្កដា ការចរចាថវិកា និងបូកសរុបថវិកាចន្លោះខែសីហា និងខែកញ្ញា រីឯការអនុម័ត ដោយគណៈរដ្ឋមន្ត្រីនៅខែតុលា ព្រមទាំងការអនុម័តដោយនីតិបញ្ញត្តិចន្លោះខែវិច្ឆិកា និងខែធ្នូ។

**ឯកឧត្តម ស៊ិន ពិសិដ្ឋ** ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានបង្ហាញពីវឌ្ឍនភាព នៃការអនុវត្ត ស.ជ.ណ ២១៣ ដូចខាងក្រោម៖

- កិច្ចប្រជុំអន្តរក្រសួង ត្រូវបានរៀបចំឡើងនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ដោយមានការចូលរួមពីតំណាងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងមុខងារសាធារណៈ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម។
- ទទួលបានការឆ្លើយតបពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវលិខិតចំនួនពីរ គឺលិខិតលេខ ៦៤៩០ សហវ/អសប ចុះថ្ងៃសុក្រ៤កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ រាជធានីភ្នំពេញថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៩ និងលិខិត៨០២៧ សហវ/អសប ចុះថ្ងៃចន្ទ៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ រាជធានីភ្នំពេញថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩។
- សិក្ខាសាលាបង្ហាញលទ្ធផលនៃការសិក្សាលទ្ធភាពនៃការបញ្ជ្រាបការងារអេដស៍ ទៅក្នុងផែនការអភិវឌ្ឍឃុំសង្កាត់ និងវិនិយោគឃុំសង្កាត់។
- បទបង្ហាញស.ជ.ណ ២១៣ នៅក្នុងកិច្ចប្រជុំ TWG on Heath នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។
- ទស្សនកិច្ចពិនិត្យការបណ្តុះបណ្តាលឃុំ សង្កាត់ស្តីពី ការរៀបចំផែនការ និងថវិកាវិនិយោគ នៅខេត្តកំពង់ចាម នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩។

ឯកឧត្តម ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានបង្ហាញពីក្រសួងដែលបានលើកផែនការសកម្មភាព ផែនការថវិកា និងថវិកាបានទទួល។

| ល.រ. | ក្រសួង ស្ថាប័ន | ផែនការសកម្មភាព | ផែនការថវិកា | បានថវិកា |
|---|---|---|---|---|
| ១ | ផែនការ | √ | √ | √ |
| ២ | អប់រំ យុវជន និងកីឡា | √ | √ | √ |
| ៣ | ធនធានទឹក និងឧតុនិយម | √ | √ | √ |
| ៤ | ប្រៃសណីយ៍ និងទូរគមនាគមន៍ | √ | √ | √ |
| ៥ | សាធារណការ និងដឹកជញ្ជូន | √ | √ | √ |

| | | | | |
|---|---|---|---|---|
| ៦ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | √ | √ | √ |
| ៧ | អភិវឌ្ឍជនបទ | √ | √ | √ |
| ៨ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | √ | √ | √ |
| ៩ | វប្បធម៌ និងវិចិត្រសិល្បៈ | √ | √ | √ |
| ១០ | កាកបាទក្រហមកម្ពុជា | √ | √ | √ |
| ១១ | អគ្គបញ្ជាការដ្ឋាន | √ | √ | √ |
| ១២ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ | √ | √ | √ |
| ១៣ | សង្គមកិច្ច និងអតីតយុទ្ធជន | √ | √ | 0 |
| ១៤ | កិច្ចការនារី | √ | √ | √ |
| ១៥ | ឧស្សាហកម្ម និងសិប្បកម្ម | √ | 0 | 0 |
| ១៦ | បរិស្ថាន | 0 | √ | 0 |
| ១៧ | ទេសចរណ៍ | √ | 0 | 0 |
| ១៨ | ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | √ | 0 | 0 |
| ១៩ | ធម្មការ និងសាសនា | √ | 0 | 0 |

**ការផ្តល់មតិយោបល់**

ការលើកសកម្មភាពឆ្លើយតបមេរោគអេដស៍ក្នុងអនុកម្មវិធីណាមួយបញ្ជ្រាបជាមួយផែនការមេរបស់ក្រសួងត្រូវមានការឯកភាពរដ្ឋមន្ត្រីសាមីក្រសួងជាមុនសិន។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍គួរចេញលិខិតមួយ ជូនដំណឹងទៅថ្នាក់ដឹកនាំក្រសួងស្ថាប័នជាសមាជិកស្តីពី ការលើកសកម្មភាពឆ្លើយតបមេរោគអេដស៍ បញ្ជ្រាបចូលក្នុងផែនការមេរបស់ក្រសួង។

**ឯកឧត្តម ឈឹម យិនដារ៉េត** អគ្គលេខាធិការប្រធានអង្គប្រជុំ បានថ្លែងអំណរគុណជូនដល់ សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានចូលរួមបច្ចេកទេសក្នុងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលពហុវិស័យ ប្រយុទ្ធនឹងជំងឺអេដស៍ និងសូមបន្ត

សម្របសម្រួលកិច្ចការដែលនៅសេសសល់មិនទាន់បានបញ្ចប់។ ឯកឧត្តម ក៏បានស្នើសុំសមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសជំរុញលទ្ធភាពកំណត់ និងដាក់បញ្ចូលបទអន្តរាគមន៍ សកម្មភាពឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងផែនការប្រតិបត្តិរបស់ក្រសួង ស្ថាប័ន។

កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានកំណត់កាលបរិច្ឆេទ សម្រាប់កិច្ចប្រជុំលើកទី៣ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០។

**ឧបសម្ព័ន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃព្រហស្បតិ៍ ទី១២កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០

បានឃើញ និងឯកភាព

**អគ្គលេខាធិការ**

បានពិនិត្យត្រឹមត្រូវ

ប្រធាននាយកដ្ឋាន

ទាក់ទង និងចលនាប្រភពធនធាន

អ្នកធ្វើរបាយការណ៍